ស្ថានទូតអូស្ត្រាលី
ប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្ដីប្រកាសព័ត៌មានរួម

*ថ្ងៃទី២១ ខែឧសភា ឆ្នាំ២០២៦*

## អូស្ត្រាលី និងកម្ពុជា ប្រកាសដាក់ឱ្យដំណើរការកម្មវិធីចម្បងស្ដីពីភាពធន់នឹងអាកាសធាតុ

រដ្ឋាភិបាលអូស្ត្រាលី និងរាជរដ្ឋាភិបាលកម្ពុជា នៅថ្ងៃនេះបានរួមគ្នាដាក់ឱ្យដំណើរការជាផ្លូវការនូវកម្មវិធី ភាពជាដៃគូអូស្ត្រាលី កម្ពុជា ដើម្បីភាពធន់នឹងអាកាសធាតុ ហៅកាត់ថា ACP4Climate ដែលជាគំនិតផ្ដួចផ្ដើមចម្បងមួយក្នុងការគាំទ្រដល់អភិបាលកិច្ចទឹកដែលមានភាពធន់នឹងអាកាសធាតុ និងការគ្រប់គ្រងធនធានទឹកចម្រុះនៅក្នុងប្រទេសកម្ពុជា ។

ការប្រែប្រួលអាកាសធាតុកំពុងជះឥទ្ធិពលកាន់តែខ្លាំងឡើងៗ ដល់ប្រព័ន្ធទឹក កសិកម្ម ជីវភាពរស់នៅ និងសហគមន៍នានានៅក្នុងប្រទេសកម្ពុជា ។ ការពង្រឹងអភិបាលកិច្ចទឹក គឺមានសារៈសំខាន់ខ្លាំងណាស់ក្នុងការបង្កើនភាពធន់ទៅនឹងការជន់លិច គ្រោះរាំងស្ងួត និងការប្រែប្រួលលក្ខខណ្ឌអាកាសធាតុ ។

ហេតុដូច្នេះហើយ តាមរយៈកម្មវិធី ACP4Climate ប្រទេសអូស្ត្រាលីនឹងជួយដល់ប្រទេសកម្ពុជា ក្នុងការពង្រឹងប្រព័ន្ធអភិបាលកិច្ចទឹក ការកែលម្អភាពធន់នឹងអាកាសធាតុ និងការលើកកម្ពស់វិធីសាស្ត្រគ្រប់គ្រងធនធានទឹកដែលប្រកបដោយបរិយាបន្ន និងមានការចូលរួមពីសហគមន៍ នៅក្នុងអាងទន្លេសំខាន់ៗ រួមមានអាងទន្លេមេគង្គលើ អាងទន្លេមេគង្គក្រោម និងអាងទន្លេសាប។

តាមរយៈកម្មវិធីនេះ យើងនឹងសហការជាមួយស្ថាប័នរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ស្ថាប័នសិក្សា ដៃគូវិស័យឯកជន និងសហគមន៍មូលដ្ឋាន ដើម្បីពង្រឹងការរៀបចំផែនការទឹកថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ពង្រឹងការសម្របសម្រួល និងគាំទ្រដល់ដំណោះស្រាយការគ្រប់គ្រងទឹកប្រកបដោយភាពធន់នឹងអាកាសធាតុ។

ឯកឧត្ដម ថោ ជេដ្ឋា រដ្ឋមន្ត្រីក្រសួងធនធានទឹក និងឧតុនិយម បានមានប្រសាសន៍ថា៖ «រាជរដ្ឋាភិបាលកម្ពុជាវាយតម្លៃ ខ្ពស់ចំពោះភាពជាដៃគូជាមួយប្រទេសអូស្ត្រាលី ក្នុងការគាំទ្រដល់កិច្ចខិតខំប្រឹងប្រែងរបស់កម្ពុជាដើម្បីពង្រឹងភាពធន់នឹង ការប្រែប្រួលអាកាសធាតុ និងការគ្រប់គ្រងធនធានទឹកប្រកបដោយនិរន្តរភាព។ កម្មវិធី ACP4Climate នឹងជួយពង្រឹង ការសម្របសម្រួល ការរៀបចំផែនការ និងអភិបាលកិច្ចទឹក ដែលធន់នឹងអាកាសធាតុ ដើម្បីគាំទ្រដល់ការអភិវឌ្ឍរយៈពេលវែងរបស់កម្ពុជា ក៏ដូចជាសុខុមាលភាពរបស់ប្រជាជនផងដែរ» ។

ឯកឧត្តម ដេរិក យីប ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា បានមានប្រសាសន៍ថា៖ «អូស្ត្រាលីគឺជាដៃគូដ៏ជិតស្និទ្ធរយៈពេលវែងរបស់កម្ពុជា ក្នុងការគាំទ្រដល់ ការអភិវឌ្ឍប្រកបដោយនិរន្តរភាព កំណើនសេដ្ឋកិច្ច និងការពង្រឹងភាពធន់។ កម្មវិធី ACP4Climate គឺជាជំពូកថ្មីមួយទៀតនៅក្នុងភាពជាដៃគូនេះ ក្នុងការជួយពង្រឹងអភិបាលកិច្ចទឹក គាំទ្រដល់សហគមន៍ដែលងាយរងគ្រោះ និងកសាងភាពធន់ទៅនឹងអាកាសធាតុ» ។

នៅក្នុងពិធីដាក់ឱ្យដំណើរការកម្មវិធីនេះ តំណាងមកពីក្រសួងនានា ដៃគូអភិវឌ្ឍន៍ អង្គការមិនមែនរដ្ឋាភិបាល ស្ថាប័នសិក្សា អ្នកពាក់ព័ន្ធពីវិស័យឯកជន និងសហគមន៍មូលដ្ឋាន បានជួបជុំគ្នាដើម្បីពិភាក្សា អំពីអាទិភាពសម្រាប់អភិបាលកិច្ចទឹកដែលធន់នឹងអាកាសធាតុ និងឱកាសសម្រាប់កិច្ចសហប្រតិបត្តិការ។

តាមរយៈកម្មវិធី ACP4Climate រដ្ឋាភិបាលអូស្ត្រាលី និងកម្ពុជា បានបញ្ជាក់ជាថ្មីនូវភាពជាដៃគូដ៏យូរអង្វែង និងការប្តេជ្ញាចិត្តរួមគ្នា ក្នុងការគាំទ្រដល់ការអភិវឌ្ឍប្រកបដោយចីរភាព និងភាពធន់នឹងអាកាសធាតុរបស់កម្ពុជា តាមរយៈវិធីសាស្ត្រដែលដឹកនាំដោយសហគមន៍មូលដ្ឋាន កិច្ចសហប្រតិបត្តិការ និងសកម្មភាពអាកាសធាតុប្រកបដោយបរិយាបន្ន។

**សម្រាប់ព័ត៌មានបន្ថែម៖**

សូមទាក់ទងទៅកាន់ Media.Cambodia@dfat.gov.au